**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ៣២៦
ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៩
**<u>សាលដីកា</u>**
លេខៈ ៩១
ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០១

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០១ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ......... ជាប្រធាន
២-លោក .......... ជាចៅក្រម
៣-លោក ........... ជាចៅក្រម
៤-លោក ............ ជាចៅក្រមរបាយការណ៍
៥-លោក ............ ជាចៅក្រម
៦-លោក .............. ជាចៅក្រម
៧-លោក .............. ជាចៅក្រម
៨-លោក ............... ជាចៅក្រម
៩-លោក ................ ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**
-លោក ..................

**<u>តំណាងមហាអយ្យការ</u>**
-លោក .................. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ៤៧០ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៧ ចុះថ្ងៃទី១២ខែមេសា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ជគភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅភូមិទួលសង្កែ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ។ ឪពុកឈ្មោះ ដៃ(ស) ម្តាយឈ្មោះ ឃិម កិ(ស) ប្រពន្ធឈ្មោះ រស់ លាងអ៊ី ។

និងចុងបណ្តឹងសាទុក្ខឈ្មោះហឈ ភេទប្រុស អាយុ៤៣ឆ្នាំជាតិខ្មែរ មុខរបរ ធ្វើចំការមានទីលំនៅភូមិទួលសង្កែ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ។ ឪពុកឈ្មោះ ហួ(ស) ម្តាយឈ្មោះ ណាក់ អាន(ស) ប្រពន្ធឈ្មោះ រិក ឃី ។

**អំពីវិវាទ :** ប្ដឹងទាមទារដី

បានឃើញបណ្ដឹងសាទុក្ខលេខ២៨៤ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៩៩ របស់លោក ជគប្ដឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ២៧០ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣២៩ ចុះថ្ងៃទី២៧ខែតុលា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី២៧-១០-៩៤ របស់លោក ហាឈ ប្ដឹងទាមទារដីពីលោក ជគដោយសំអាងហេតុថា ដីទំនាស់លោកបានកាន់កាប់ផែរក្សាតាំងពីឆ្នាំ១៩៧០ រហូតដល់សព្វថ្ងៃ លោកនៅតែថែរក្សាផលដំណាំមានចេក ឬស្សី និងផលដំណាំផ្សេងទៀតដដែល ។ នៅឆ្នាំ១៩៩២ លោក ជគបាននាំកម្មាភិបាល បុគ្គលិកសុរិយោដីខេត្ត-ស្រុក-ឃុំ និងភូមិ មកវាស់វែងចូលដីរបស់លោក ឱ្យទៅលោកជគ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៥៧ (រ) ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ១៩៩៥ របស់តុលាការខេត្តកណ្ដាល សម្រេចចំពោះមុខគូក្ដី ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី២៧-១០-១៩៩៤ របស់ឈ្មោះ ហាឈ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយ និងគតិច្បាប់ ។

២- បដិសេធចោលជាអសារបង់នូវប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខE7 00៧១ ចុះថ្ងៃទី០៤ខែ មីនាឆ្នាំ១៩៩២ របស់ភូមិបាលស្រុកកោះធំ ដោយគ្មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

៣- ប្រគល់ដីទំនាស់ទំហំ៨៥០ម៉ែត្រx ៣០ម៉ែត្រ ដែលមានព្រំប្រទល់គឺ ៖

-ខាងជើងទល់ដី ប៉ាត វិច

- ខាងត្បូងទល់ដី អេង ហែន

-ខាងកើតទល់ដី ខុម គី

- ខាងលិចទល់ដី ង៉ូវ សៀ

ស្ថិតនៅភូមិទួលសង្កែ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្ដាល ឱ្យទៅឈ្មោះ ដៃ គត(ចុងចម្លើយ) កាន់កាប់ និងគ្រប់គ្រងជាកម្មសិទ្ធិចាប់ពីថ្ងៃផុតកំណត់នៃបណ្ដឹងឧទ្ធរណ៍ ។ ឱ្យឈ្មោះជគទៅធ្វើប័ណ្ណសម្គាល់សិទ្ធិជាថ្មី នៅភូមិបាល ស្រុកកោះធំ ។

៤- ឱ្យឈ្មោះ ហាឈ (ដើមចោទ) បង់ប្រាក់ប្រដាប់ក្ដី សរុប ៧០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង១.៨០០៛ រង្វាន់ក្រឡាបញ្ជី២០០៛ ពន្ធស៊ើបសួរ ៥.០០០៛ ។ ប្រាក់នោះដើមចោទបានបង់រួចហើយ ហើយដាក់កំហុសលើដើមចោទ ។

សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោនមុខគួភាគី គួភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេល២ខែគិតពីថ្ងៃនេះតទៅ ។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខ១១៩ ចុះថ្ងៃទី២៥-១២-៩៥ របស់ឈ្មោះ ហាឈ ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចកិច្ចការប្រញាប់លេខ៥៧(រ)ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ១៩៩៥ របស់តុលាការខេត្តកណ្តាល លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៥៣៧ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ:

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥-១២-៩៥ របស់ឈ្មោះ ហាឈ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៥៧ (រ) ចុះថ្ងៃទី០៤-១២-៩៥ របស់តុលាការខេត្តកណ្តាល ចោលជាអសារបង់ ។

៣- ប្រគល់ដីទំនាស់ទំហំ៨៥០ម៉ែត្រ ដែលមានព្រំប្រទល់:

-ខាងជើងទល់ដី ប៉ាត វិច

-ខាងត្បូងទល់ដី អេង ហែន

-ខាងកើតទល់ដី ខុម គី

-ខាងលិចទលំដី ជគ

ស្ថិតនៅភូមិទួលសង្កែ ឃុំកំពង់កុង ស្រុកកោះធំខេត្តកណ្តាលឱ្យទៅឈ្មោះហាឈ កាន់កាប់ជាកម្មសិទ្ធិតទៅ :

-បង្គាប់ឱ្យឈ្មោះ ដៃ គត សុំអាជ្ញាធរមានសមត្ថកិច្ចកែតម្រូវប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខE700៧១ ចុះថ្ងៃទី០៤-០៣-៩២ របស់ភូមិបាលស្រុកកោះធំ ខេត្តកណ្តាល ជាថ្មីឱ្យបានត្រឹមត្រូវតាមការកាន់កាប់របស់ខ្លួនវិញ ។

៤- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ ចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

-បង្គាប់ឱ្យឈ្មោះ ជគបង់ពន្ធសមាមាត្រ១% នៃតម្លៃដីទាស់ ។

៥- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៣៨ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧ របស់លោកជគដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៥៣៧ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ របស់តុលាការកំពូលសម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលបណ្តឹងសាទុក្ខលេខ៣៨ ចុះថ្ងៃទី១៤-១០-៩៧ របស់លោក ជគទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៥៣៧ ចុះថ្ងៃទី១១-០៩-៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣៨៧ ចុះថ្ងៃទី០៨ ខែធ្នូឆ្នាំ១៩៩៧ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីដែលលោក ជគបានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ៊ឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥០០០រៀល សរុប១៩០០០រៀល ហើយតម្រូវឱ្យលោក ហឈ សងប្រាក់ចំនួន១៩០០០រៀល នេះទៅលោក ជគវិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៧។

បានឃើញ ដីកាបញ្ជូនលេខ១២៣ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍វិញ ដើម្បីចាត់ការតាមច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៧០ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ១៧ ចុះថ្ងៃទី១២-០៤-៩៩ របស់សាលាឧទ្ធរណ៍ ដោយអំណាចសាលដីការដ្ឋប្បវេណីលេខ៤៦ ចុះថ្ងៃទី១១-០៣-៩៩ របស់តុលាការកំពូល ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៥៧(រ) ចុះថ្ងៃទី០៤-១២-៩៥ របស់តុលាការខេត្តកណ្តាលចោលជាអសារបង់ ។

៣- ប្រគល់ដីទំនាស់ទំហំ៨៥០ម x ៣០ម ដែលមានព្រំប្រទល់:

-ខាងជើងទល់ដី ប៉ាត វិច

-ខាងត្បូងទល់ដី អេង ហែន

- ខាងកើតទល់ដី ឧម គី

- ខាងលិចទល់ដី ជគ

ស្ថិតនៅភូមិទួលសង្កែ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ឱ្យទៅឈ្មោះ ហឈ កាន់កាប់ ជាកម្មសិទ្ធិតទៅ ។

៤- កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ដីកាកោះ៥០០០៛ អាជ្ញាធរតុលាការ៥០០០៛ ។

៥- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខតាម កំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ២៨៤ ចុះថ្ងៃទី០៩ខែសីហាឆ្នាំ១៩៩៩ របស់លោកឧទ្ធរណ៍លើសេចក្ដីសម្រេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៩ របស់ឈ្មោះជគបានឃើញសារណាតប ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០០ របស់ឈ្មោះហឈ

- បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា

បណ្ដឹងសាទុក្ខរបស់ដើមចោទស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះពិនិត្យពិចារណា ។

-សាលដីការដ្ឋប្បវេណីលេខ៤៧០ ចុះថ្ងៃទី១៩-០៧-១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្ដីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្ដាសម្រេចទាំងអង្គហេតុទាំងអង្គច្បាប់ ។

បានស្ដាប់ចម្លើយរបស់លោក ជគឆ្លើយថាការធ្វើប័ណ្ណកម្មសិទ្ធិនេះ គឺបានធ្វើឡើងត្រឹមត្រូវតាមច្បាប់ទាំងអស់ និងខ្ញុំបាទមិនសុខចិត្តពីសាលដីការបស់សាលាឧទ្ធរណ៍ ដែលបានកាត់សេចក្ដីមិនត្រឹមត្រូវឡើយ ។

បានស្ដាប់ចម្លើយរបស់លោក ហឈ ឆ្លើយថា: បើគាត់បានកាន់កាប់ និងមានប័ណ្ណកម្មសិទ្ធិពិតប្រាកដមែននោះ ហេតុអ្វីបានជាគាត់ទើបមកប្ដឹង ។

នៅលើដីទំនាស់នេះខ្ញុំបាទបានដាំចេកប្រហែល១៥ដើម ព្រមទាំងមើលថែទាំទទួលផលរហូតមក

-ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយដោះសារ របស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

# តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ២៨៤ ចុះថ្ងៃទី០៩-០៨-៩៩ របស់លោក ជគស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះ ទាំងអង្គហេតុ ទាំងអង្គច្បាប់បានតាមមាត្រា ១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងមាត្រា២២៦ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចប្រគល់ដីទំហំ៨,៥០មx៣០មឱ្យលោកហឈ ដោយអាងហេតុថា នាពេលសវនាការនៅសាលាឧទ្ធរណ៍ លោក ជគបានឆ្លើយទទួលស្គាល់ថា ដើមបណ្ដឹងឧទ្ធរណ៍បានដាំឬស្សី និងកាន់កាប់ឬស្សីនេះរហូតមកជាការភ័ន្ដច្រឡំ ព្រោះថាក្នុងកំណត់ហេតុជំនុំជំរះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១១-០៩-៩៩ ពុំមានចម្លើយណាមួយដែលថា លោក ជគទទួលស្គាល់ដូចដែលសាលាឧទ្ធរណ៍សំអាងនោះឡើយ ។

-យល់ឃើញថា ដីទំនាស់នេះត្រូវបានរដ្ឋអំណាចភូមិ-ឃុំ ប្រគល់ឱ្យលោក ដែគត តាំងពីឆ្នាំ ១៩៨១ ប៉ុន្ដែតាមការបញ្ជាក់របស់លោកមេឃុំ ហ៊ឹង ហ៊ាង ចុះថ្ងៃទី១២-១១-៩៤ ថាគូភាគីធ្លាប់មានទំនាស់នឹងគ្នាហើយតាមការសម្រុះសម្រួលបានឯកភាពព្រមព្រៀងបែងចែកដីនេះ ជាពីរចំណែកគឺ១៥មx៨,៥ម ម្នាក់ ។ ដូច្នេះតុលាការគប្បីពិចារណាលើការព្រមព្រៀងនេះ ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៤៧០ ចុះថ្ងៃទី១៩-០៧-៩៩ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្ដីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## និច្ឆ័យសេចក្ដីចំពោះមុខគូក្ដី

១- ទទួលបណ្ដឹងសាទុក្ខលេខ២៨៤ ចុះថ្ងៃទី០៩-០៨-៩៩ របស់លោក ជគទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៤៧០ ចុះថ្ងៃទី១៩-០៧-៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- ទុកជាមោឃៈប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខE700៧១ ចុះថ្ងៃទី០៤-០៣-១៩៩២ របស់ភូមិបាលស្រុកកោះធំ ។

៤- បែងចែកដីទំនាស់ទំហំ៨,៥០មx៣០មឱ្យលោកដៃ គតនិងលោកហួឈុនម្នាក់ពាក់កណ្ដាល ។

៥- រឹបអូសប្រាក់ប្រដាប់ក្ដី ដែលលោក ជគបានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្ដែប្រាក់នេះ ត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយក្នុងការប្រគល់ដីកាកោះចំនួន១៥០០០រៀលសរុប១៩០០០រៀលហើយតម្រូវ ឱ្យលោក ហាឈ សងប្រាក់ចំនួន១៩.០០០រៀល នេះទៅលោក ជគវិញ ។

បង្គាប់ឱ្យលោក ហាឈ និងលោក ជគបង់ពន្ធសមាមាត្រ១%លើតម្លៃដីទំនាស់ពាក់កណ្តាល ម្នាក់ ។

៦- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០១។